**នៅពេលឆ្នាំសិក្សាត្រូវបញ្ចប់ គឺគម្រោង និង ការត្រៀមទុកនៅតែបន្តធ្វើ**

ជម្រាបជូនសហគមន៍នៃក្រសួងអប់រំ ឪស្រ្ទីគ ឡុងប៊ីច

ជាងប៉ុន្មានសប្ដាហ៍កន្លងមក គឺជាពេលចុងក្រោយបង្អស់ ដែលនាងខ្ញុំបានផ្ញើសារទៅកាន់សហគមន៍ ។ តាំងពីពេលនោះមក មានសាលារៀនទាំងអស់បានទទួលស្វាគមន៍សិស្សកាន់តែច្រើននាក់ត្រឡប់ចូលរៀនវិញ ដោយនៅពេលជាមួយគ្នា គឺនៅតែបន្តធ្វើផងដែរអំពីការផ្ដល់កម្មវិធីរៀនពីចម្ងាយ ។ ក្រុមកីឡាបានប្រកួតស្របតាមរដូវផ្លាស់ប្ដូរ និង កម្មវិធីសម្ដែងដោយសិស្សត្រូវបានចាប់ផ្ដើមឡើង ។ នៅពេលសារនេះផ្ញើទៅដល់លោកអ្នក គឺយើងបានធ្វើពិធីអបអរបញ្ចប់ថ្នាក់សិក្សារួចទៅហើយសម្រាប់សិស្សថ្នាក់ទី ដប់ពីរ នៅឯសាលារៀន Sato និង CAMS ។ បញ្ហាទាក់ទងផ្នែកសុខភាពសហគមន៍ គឺមានភាពកាន់តែប្រសើរឡើងនៅតាមតំបន់សហគមន៍ ។ នាងខ្ញុំបានទទួលបទពិសោធន៍ផ្ទាល់អំពីភាពអរសប្បាយនៅពេលឃើញសិស្សក្នុងសាលារៀន នៅតាមទីធ្លារត់លេង និង ការចូលរួមចំណែកផ្សេងៗក្នុងព្រឹត្តិការណ៍សាលារៀនរបស់យើង ។ កម្មវិធីជាកម្រិតខ្ពស់បំផុតប្រចាំឆ្នាំនឹងមានដូចជា ពិធីអបអរបញ្ចប់ថ្នាក់សិក្សា ពិធីឡើងថ្នាក់ និង កម្មវិធីចុងបញ្ចប់ឆ្នាំសិក្សាផ្សេងៗជាច្រើនមុខទៀត ដែលសិស្សរបស់យើងកាន់ភ្ជាប់ និង ក្រសោបយកស្របតាមបទពិសោធន៍សាលារៀនរបស់ពួកគេ ។

ឆ្នាំឆ្លងកាត់ជម្ងឺរាលដាលបាននាំមកជាបញ្ហាខូចខាតទៅកាន់ប្រជារាស្រ្តជាច្រើននៅតាមសហគមន៍ ដែលរាប់បញ្ចូលផងទាំងបុគ្គលិកខិតខំរបស់យើង ។ នៅពេលយើងត្រៀមទុកសម្រាប់បិទឆ្នាំសិក្សាស្របច្បាប់ក្នុងឆ្នាំនេះ គឺនាងខ្ញុំមានសេចក្ដីសង្ឃឹមថា លោកអ្នកនឹងចូលរួមជាមួយនាងខ្ញុំ ដើម្បីថ្លែងអំណរគុណទៅកាន់បុគ្គលិកជាង 10,000 នាក់ ដែលបំពេញកិច្ចការនៅក្នុងសហគមន៍ LBUSD ។ មុខងារនៃកម្មវិធីសិក្សា គឺជា "កិច្ចការទាក់ទងមនុស្ស" ។ វាតម្រូវឱ្យម្នាក់ៗបំពេញមុខងាររួមគ្នា ដើម្បីបញ្ជាក់ថា សិស្សគ្រប់រូបរបស់យើងបានទទួលជាអ្វីស្របតាមសេចក្ដីត្រូវការមែនសម្រាប់លទ្ធផលជោគជ័យ ហើយសូម្បីតែកិច្ចការខ្លះៗ ដែលបុគ្គលិកបានធ្វើ និង មិនសូវបានទទួលការយកចិត្តទុកដាក់ទៅកាន់ក៏ដោយ ក៏នៅតែអាចនាំមកជាប្រយោជន៍យ៉ាងច្រើនផងដែរសម្រាប់ជិវិតនៃសិស្សរបស់យើង ។

នៅពេលបិទសាលារៀន គឺយើងខិតខំធ្វើការសង្កត់មកលើគោលដៅដ៏សំខាន់ៗ និង ការប្រឹងប្រែងបង្ហាញភាពលូតលាស់របស់យើង ។ យើងបានទ្រទ្រង់ទុកជាកម្រិតខ្ពស់អំពីចំនួនសិស្ស ដែលបានចូលរៀនប្រចាំថ្ងៃ ។ ការរៀននៅតែបានធ្វើជាបន្ត ។ យ៉ាងណាក៏ដោយ គឺគ្រាឆ្លងកាត់ជម្ងឺរាលដាលក៏បានបង្ហាញដែរអំពីភាពមិនស្មើគ្នានៅក្នុងសង្គម ដែលប៉ះពាល់ច្រើនជាងគេទៅកាន់ប្រជារាស្រ្តមានភាពក្រីក្រស្រាប់មកហើយ រាប់បញ្ចូលផងទាំងជនជាតិផ្សេងៗជាជនជាតិភាគតិច ។

សហគមន៍ និង ប្រព័ន្ធសាលារៀនរបស់យើងក៏បានទទួលលទ្ធផលប៉ះពាល់ដែរអំពីអំពើប្រកាន់ពូជសាសន៍ និង អយុត្តិធម៌ ដែលមានជាយូរមកហើយ ។ ក្នុងគ្រាឆ្លងកាត់ជម្ងឺរាលដាល និង ការរង្កៀសចិត្តគ្នា គឺយើងបានប្រឹងប្រែងបន្តប្រើមធ្យោបាយសារឡើងវិញសម្រាប់ធ្វើការទាក់ទងទៅកាន់សហគមន៍ជាភាពចម្រុះរបស់យើង ដើម្បីពិគ្រោះអំពីសមធម៌ និង ប្រព័ន្ធប្រកាន់ពូជសាសន៍ ដោយចាប់ផ្ដើមប្រើគំនិតជាចំណែកៗសម្រាប់សមធម៌ និង ឧត្តមភាព - រាប់ទាំងការយកចិត្តទុកដាក់ជួលបុគ្គលិក - ដែលនឹងធ្វើជាបន្តក្នុងចំនួនខែ និង ឆ្នាំទៅមុខ ។ គ្រាឆ្លងកាត់ជម្ងឺរាលដាល និង បញ្ហាស្មុគស្មាញក្នុងសង្គមបានបង្កើតជាការសាកល្បងធ្វើមួយ ដែលជួយយើងបង្កើនទំនាក់ទំនងជាអត្ថន័យ និង ភាពស្មោះត្រង់កាន់តែប្រសើរជាមួយក្រុមរួមចំណែកផ្សេងៗរបស់យើង ។ ក្នុងការផ្ដល់ជំនួយទៅកាន់សេចក្ដីត្រូវការផ្សេងៗនៃសិស្សរបស់យើង គឺមានបុគ្គលិក ដែលបំពេញមុខងារស្របតាមវិជ្ជាសញ្ញាប័ត្រ (ប្រហែលជា 3800 នាក់ ដែលមានជា គ្រូបង្រៀន នាយកសាលា អ្នកផ្ដល់ឪវាទ បុគ្គលិកផ្ដល់ជំនួយទូទៅ) នឹងចូលរួមក្នុងកម្មវិធីហ្វឹកហ្វឺនផ្នែកសមធម៌នៅរដូវក្ដៅនេះ ហៅ Summer Equity Institute ។ បុគ្គលិកនឹងមានឪកាសរៀនប្រើមធ្យោបាយថ្មីៗសម្រាប់បង្កើតជាទំនាក់ទំនងផ្នែកអារម្មណ៍ និង ផ្លូវចិត្តជាមួយសិស្ស បណ្ដុះការយល់ដឹងអំពីការបង្ហាត់មេរៀនទាក់ទងផ្នែកវប្បធម៌ និង ស្វែងរកមធ្យោបាយផ្សេងៗសម្រាប់ពង្រឹងបទពិសោធន៍នៅតាមបន្ទប់រៀន ដែលបង្កើនជាចំណងយ៉ាងស្និទ្ធស្នាលរវាងទំនាក់ទំនងនៃសិស្ស និង គ្រូបង្រៀន ។ យើងមានសេចក្ដីរីករាយអំពីការចាប់ផ្ដើមឆ្នាំសិក្សា 2021-22 ជាមួយឪកាសរៀនសាកល្បងរបៀបនេះ ។

ក្រៅតែពីកម្មវិធីហ្វឹកហ្វឺន គឺមានក្រុមដឹកនាំផ្នែកសមធម៌ ដែលមានសមាជិកជា សិស្ស មាតាបិតា បុគ្គលិក និង ក្រសួងដៃគូនៅតាមសហគមន៍ បានជួបជុំគ្នាជាច្រើនលើក ហើយនឹងលើកផ្តល់ជាអនុសាសន៍សម្រាប់ការផ្តើមគំនិតប្រើច្បាប់ ការអនុវត្តន៍ផ្សេងៗ ថវិកា និង អ្វីផ្សេងទៀតសម្រាប់គិតគូរទៅថ្ងៃមុខ ។ ច្បាប់សមធម៌ ដែលកំពុងទទួលការរៀបចំ គឺនឹងប្រើជាផ្លូវការ ស្របតាមសេចក្តីប្តេជ្ញាជាក្រុមសម្រាប់ឆ្ពោះទៅកាន់ឧត្តមភាព និង សមធម៌ជាទូទៅនៅក្នុងក្រសួងអប់រំ LBUSD ។

យើងដឹងហើយថា យើងនៅមានកិច្ចការមិនទាន់បញ្ចប់ខ្លះៗ ដែលនឹងធ្វើជាមួយ នៅពេលឆ្នាំសិក្សាថ្មីចាប់ផ្តើម ។ គម្រោងផ្តល់ជំនួយសម្រាប់បង្កើនល្បឿនផ្នែកសិក្សារបស់យើង គឺកំពុងតែរៀបចំឱ្យរួចដាច់ស្រេច និង មានតាំងបង្ហាញជាសាធារណៈក្នុងខែសីហា ។ យើងបានចាប់ផ្តើមរៀបជាគម្រោងនេះស្របតាមសេចក្តីត្រូវការនៃសិស្ស ដោយរាប់បញ្ចូលគ្នាជាធនធានច្រើនចំណែក រួមទាំងការប្រើថវិកាថ្មីៗជាចំនួនដ៏ច្រើនសម្រាប់ដោះស្រាយក្នុងគ្រាឆ្លងកាត់ជម្ងឺរាលដាល ដែលបានទទួលមកពីរដ្ឋ និង រដ្ឋាភិបាលជាតិ ដើម្បីផ្តល់ឱកាសរៀនដ៏ល្អបំផុត និង ជំនួយផ្សេងៗទាក់ទងគ្នា ។ បើសិនជាលោកអ្នកមានបំណងចង់ដឹងបន្ថែមអំពីគម្រោង គឺសូមបើកមើលនៅតាម វិដេអូ យូធូបដែលបានលើកបង្ហាញនៅក្នុងកិច្ចប្រជុំគណៈកម្មការសាលារៀននៅថ្ងៃទី17 និង 26 ខែឧសភា និង ថ្ងៃទី2 ខែមិថុនា ។

យើងមានជំនឿថា កម្មវិធីបង្ហាត់មេរៀននៅក្នុងថ្នាក់ផ្ទាល់ និង ឱកាសសម្រាប់ផ្តល់ជំនួយគាំទ្រទូទៅទៅកាន់ក្រុមគ្រួសារ គឺអាចធ្វើទៅបានយ៉ាងល្អជាមួយសិស្សនៅក្នុងសាលារៀនរបស់យើង ។ ដោយមូលហេតុនេះ យើងនឹងធ្វើការជម្រុញឱ្យសិស្សទាំងអស់ត្រឡប់ចូលសាលារៀនវិញសម្រាប់រៀននៅតាមថ្នាក់ពេញថ្ងៃជាមួយកម្មវិធីពេញកម្រិត ។ ច្រកផ្លូវសម្រាប់ការត្រឡប់ចូលសាលារៀនវិញនឹងមានភាពខុសៗពីគ្នារវាងក្រុមគ្រួសារ ។ ក្រុមគ្រួសារខ្លះនឹងប្រើកម្មវិធីរៀនរដូវក្តៅសម្រាប់ជួយសិស្សប្រែត្រឡប់ចូលរៀនក្នុងថ្នាក់ផ្ទាល់វិញ ។ ក្រុមគ្រួសារផ្សេងទៀតនឹងរង់ចាំដល់ពេលសាលារៀនចាប់ផ្តើមបើកឡើងវិញនៅខែសីហា ទើបផ្លាស់ឱ្យសិស្សត្រឡប់ចូលរៀនក្នុងថ្នាក់ផ្ទាល់វិញ ។ នៅពេលយើងកំពុងត្រៀមបើកសាលារៀនឡើងវិញយ៉ាងពេញកម្រិតក្នុងខែសីហា គឺបុគ្គលិកនឹងបំពេញមុខងារពេញរដូវក្តៅសម្រាប់ទាក់ទងទៅកាន់ក្រុមគ្រួសារទាំងឡាយណា ដែលប្រហែលជាត្រូវការជំនួយបន្ថែមសម្រាប់បញ្ជូនសិស្ស "ត្រឡប់ចូលសាលារៀនវិញ" និង ដើម្បីបញ្ជាក់ថា យើងបានធ្វើសព្វយ៉ាងស្របសមត្ថភាពមែនសម្រាប់ស្វែងរក និង ផ្តល់សេចក្តីយកចិត្តទុកដាក់ទៅកាន់សិស្សគ្រប់រូបនៅក្នុងសហគមន៍របស់យើង ។

ក្រសួងអប់រំ ឌីស្រ្ទីគ របស់យើងកំពុងស្ថិតនៅក្នុងឋានៈដ៏ល្អអំពីការចាប់ផ្តើមភាពលូតលាស់តាមសម័យថ្មីសម្រាប់សិស្សគ្រប់រូប ក្រោមការយកចិត្តទុកដាក់របស់យើង ។ ចំពោះលោកអ្នកទាំងអស់ ដែលបានគាំទ្រមកកាន់សាលារៀននៅក្នុងគ្រាមួយដ៏សែនលំបាក គឺនាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រៅជ្រះ ហើយនាងខ្ញុំសូមអញ្ជើញដល់លោកអ្នកឱ្យនៅតែបន្តដំណើររួមជាមួយយើង ដែលភ្ជាប់ដោយសេចក្តីសង្ឃឹមខ្ពស់សម្រាប់សិស្សរបស់យើង ។

ដោយសេចក្តីស្មោះ

Jill A. Baker, Ed. D.
អគ្គនាយកសាលារៀន